00401277

E159/8

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 11 / 11 / 2009
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ការដាក់តម្កល់ឯកសារ**

**សំណុំរឿងលេខ៖** ០០១/១៨-០៧-២០០៧-អ.វ.ត.ក(អ.ជ.ស.ដ)

**ភាគីអ្នកតម្កល់៖** សហមេធាវីរបស់លោក **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច**

**ដាក់តម្កល់ជូន៖** អង្គជំនុំជម្រះសាលាដំបូង

**ភាសាដើម៖** ភាសាបារាំង

**កាលបរិច្ឆេទដាក់ឯកសារ៖** ១១ វិច្ឆិកា ២០០៩

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ស្នើដោយភាគីអ្នកដាក់តម្កល់៖ **សាធារណៈ**

ចំណាត់ថ្នាក់សម្រេចដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ៖

លក្ខន្តិកៈនៃចំណាត់ថ្នាក់៖

ការពិនិត្យចំណាត់ថ្នាក់បណ្ដោះអាសន្នឡើងវិញ៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿងនិងឯកសារ៖

ហត្ថលេខា៖

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification): 12 / NOV / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier:

## សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្ដី

បញ្ជូនដោយ៖

**មេធាវីរបស់ជនជាប់ចោទ**

លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច

មេធាវី ការ សាវុត្ថ

មេធាវី François ROUX

មេធាវី Marie-Paule CANIZARES

បញ្ជូនទៅ៖

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង**

លោកចៅក្រម និល ណុន (ប្រធាន)

លោកស្រីចៅក្រម Silvia CARTWRIGHT

លោកចៅក្រម យ៉ា សុខន

លោកចៅក្រម Jean-Marc LAVERGNE

លោកចៅក្រម ធូ មណី

ចម្លងជូន៖

សហព្រះរាជអាជ្ញា

លោកស្រី ជា លាង

លោក William SMITH

<u>ចម្លងជូន៖</u>

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោកមេធាវី គង់ ពិសី

លោកមេធាវី ហុង គឹមសួន

លោកមេធាវី យុង ផានិត

លោកមេធាវី គឹម ម៉េងឃី

កញ្ញាមេធាវី ម៉ុច សុវណ្ណារី

កញ្ញាមេធាវី ទី ស្រីនណា

លោកស្រីមេធាវី Silke STUDZINSKY

លោកស្រីមេធាវី Martine JACQUIN

លោកមេធាវី Philippe CANNONE

លោកមេធាវី Pierre Olivier SUR

លោកមេធាវី Alain WERNER

លោកមេធាវី Brianne McGONIGLE

លោកស្រីមេធាវី Annie DELAHAIE

លោកស្រីមេធាវី Elizabeth RABESANDRATANA

លោកមេធាវី Karim KHAN

លោកស្រី Fabienne TRUSSES-NAPROUS

លោកស្រីមេធាវី Christine MARTINEAU

# សូមគោរពជូនអង្គជំនុំជម្រះសាលាដំបូង

## I. សេចក្តីផ្តើម

១. អង្គជំនុំជំម្រះសាលាដំបូងបានបង្គាប់ដល់ភាគីទាំងអស់ ឲ្យដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោល ដើម្បីធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ក្នុងអំឡុងពេលនៃអង្គសវនាការ ដូចមានចែងនៅក្នុងវិធាន៩៤ នៃវិធានផ្ទៃក្នុង យ៉ាងយូរបំផុតត្រឹមថ្ងៃទី១១ ខែវិច្ឆកា ឆ្នាំ២០០៩ [1]។

២. ដោយសារហេតុផលថា ក្រុមមេធាវីការពារក្តីមិនមានលទ្ធភាពបានដឹងជាមុន នូវសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សារបស់សហព្រះរាជអាជ្ញា និងរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីមុនថ្ងៃនេះ ដូច្នេះមេធាវីការពារក្តីសូមដាក់សារណាក្នុងទម្រង់បច្ចុប្បន្ននេះ និង សូមរក្សាសិទ្ធិបន្ថែមអំណះអំណាងដោយផ្ទាល់មាត់ នៅថ្ងៃសវនាការសម្រាប់ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។

## II. អង្គហេតុ

### ក. ការទទួលស្គាល់របស់ ឌុច ចំពោះអង្គហេតុនានាដែលលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ

៣. កាលពីថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ ក្រុមមេធាវីការពារក្តីបានដាក់ជូនអង្គជំនុំជម្រះសាលាដំបូង នូវឯកសារមួយមានចំណងជើងថា "គោលជំហររបស់ក្រុមមេធាវីការពារក្តី ចំពោះអង្គហេតុនៅក្នុងដីកាដំណោះស្រាយ" [2] ។

---

[1] សេចក្តីណែនាំស្តីពីនីតិវិធីពាក់ព័ន្ធនឹងការទាមទារសំណង និងការដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោល, អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩, E159, ERN 00367369-00367372។

[2] គោលជំហររបស់មេធាវីការពារក្តីចំពោះអង្គហេតុក្នុងដីកាដំណោះស្រាយ, ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩, E5/11/6, ERN 00294629-00294630 ; E5/11/6.1, ERN 00294634-00294678 ; E5/11/6.2, ERN 00294757-00294762..

៤. ជនជាប់ចោទបានបញ្ជាក់ក្នុងពេលជំនុំជម្រះថា ឯកសារនេះសមស្របនឹងគោលជំហររបស់គាត់ចំពោះអង្គហេតុដែលមានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

៥. ដូចដែលបានធ្វើរួចមកហើយនៅក្នុងអំឡុងពេលពិភាក្សាដេញដោលក្នុងសវនាការ ក្រុមមេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង មេត្តាពិចារណានៅក្នុងសាលក្រមរបស់ខ្លួនលើឯកសារនេះ ដែលបានបង្ហាញថា ឌុចទទួលស្គាល់ទំនួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មភាគច្រើនដែលត្រូវបានប្រព្រឹត្តនៅមន្ទីរ ស-២១ [3]។

៦. ក្រុមមេធាវីការពារក្តីយល់ឃើញថា ការដែលឌុចទទួលស្គាល់អង្គហេតុទាំងនេះគឺជាការសារភាពមួយរបស់គាត់ ហើយការសារភាពនេះបានក្លាយទៅជាទម្រង់មួយក្នុងចំណោមទម្រង់ភស្តុតាងទាំងឡាយដែលបានទទួលយកដោយវិធានផ្ទៃក្នុង [4] នៃអវតក និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា [5]។

**ខ. អវត្តមាន ឬកង្វះខាតធាតុផ្សំនៃភស្តុតាងដែលអាចបង្កើតជាអង្គហេតុដែលឌុចជំទាស់មិនទទួលស្គាល់ឱ្យលើសពីមតិសង្ស័យដែលមាន**

៧. យើងគួរកត់សម្គាល់ថា ក្នុងចំណោមអង្គហេតុទាំងអស់ដែលបានលើកឡើងនៅក្នុងកថាខណ្ឌទាំង១៣២នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានចែងនៅក្នុងឯកសារខាងលើនេះ គឺមានអង្គហេតុតែ៣៣ប៉ុណ្ណោះ ដែលឌុចនៅតែបន្តជំទាស់តទៅទៀត ។

---

[3] សូមអាន ឧបសម្ព័ន្ធ ក ៖ តារាងសង្ខេបគោលជំហររបស់មេធាវីការពារក្តី ចាប់ពីកថាខណ្ឌ ១ ដល់ ៣ និង ១០ ដល់ ១២៨ ("ការបង្ហាញអង្គហេតុ") នៃដីកាបញ្ជូនរឿងទៅជម្រះ និង សូមអានឧបសម្ព័ន្ធ ខ ៖ តារាងសង្ខេបគោលជំហររបស់មេធាវីការពារក្តី ចាប់ពីកថាខណ្ឌ ១៦២ ដល់ ១៧១ ("ព័ត៌មានទាក់ទងនឹងបុគ្គលិកលក្ខណៈ") នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ

[4] វិធាន ៨៧ (៥) នៃវិធានផ្ទៃក្នុង

[5] មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

៨. ក្រុមមេធាវីការពារក្តីយល់ឃើញថា សហព្រះរាជអាជ្ញាគ្រាន់តែឈរលើមូលដ្ឋាននៃវិមតិសង្ស័យដែលខ្លួនមានតែប៉ុណ្ណោះ តែមិនបានធ្វើការបកស្រាយការចោទប្រកាន់នានាដែល**ឌុច**ជំទាស់មិនទទួលស្គាល់នៅក្នុងពេលទទួលស្គាល់អង្គហេតុ និងនៅក្នុងអំឡុងពេលជំនុំជម្រះឡើយ[6]។

៩. ជាពិសេស ដោយគ្មានមូលដ្ឋានអ្វីក្រៅពីវិមតិសង្ស័យ សហព្រះរាជអាជ្ញាមិនបានផ្តល់នូវធាតុផ្សំណាមួយដែលអាចបង្ហាញថា៖

- **ឌុច** ទំនងជាបានសម្លាប់អ្នកទោសនៅមន្ទីរ ស-២១ ដោយផ្ទាល់ដៃ
- **ឌុច** ទំនងជាបានធ្វើទារុណកម្មអ្នកទោសនៅមន្ទីរ ស-២១ ដោយផ្ទាល់ដៃ
- **ឌុច** ទំនងជាបានបញ្ជាឲ្យធ្វើការចាប់ខ្លួន ដោយគ្មានការណែនាំពីថ្នាក់លើ។

១០. អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះសាលាដំបូង មេត្តាប្រកាសឲ្យ**ឌុច**បានរួចខ្លួនពីការចោទប្រកាន់នានា។

១១. លើសពីនេះទៅទៀត ទាក់ទងនឹងឧក្រិដ្ឋកម្មតាមរយៈការប្រព្រឹត្តទារុណកម្ម ក្រោមទម្រង់នៃការចូលរួម "ប្រព្រឹត្ត" ក្រុមការពារក្តីយល់ឃើញថា ដោយអនុវត្តតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចេញថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ [7] **ឌុច**មិនមានអ្វីត្រូវឆ្លើយទាក់ទងនឹងបទឧក្រិដ្ឋកម្មនេះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងទេ ព្រោះថាអង្គជំនុំជម្រះសាលាដំបូងមិនបានលើកឡើងពីបញ្ហានេះទេ។

## III. **អង្គច្បាប់**

---

[6] សូមអានសារណារបស់ក្រុមមេធាវីការពារក្តីដើម្បីឆ្លើយតបនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០០៨ D96/1, ERN 00207941-00207952 ; និង តារាងកែតម្រូវ, ថ្ងៃទី១១ សីហា ២០០៨, D96/1/1, ERN 00211235.

[7] សេចក្តីសម្រេចទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុងសំណុំរឿងរបស់កាំង ហ្កេចអ៊ាវ ហៅ ឌុច។ អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨។ ឯកសារ D99/3/42, ERN 00270395 កថាខ័ណ្ឌ១០០ និង ERN 00270416 (ឯកសារ D99/3/42)។

## ក. បទឧក្រិដ្ឋដែលចោទប្រកាន់

### ១. បទឧក្រិដ្ឋជាតិ ទាក់ទងនឹងអំពើឃាតកម្ម និងការធ្វើទារុណកម្ម

### *ក. អញ្ញត្រកម្មបឋម*

១២. តាមរយៈសេចក្តីសម្រេចចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានបញ្ចូលបន្ថែមទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនូវការចោទប្រកាន់ពីបទល្មើសមនុស្សឃាត និងបទល្មើសនៃការធ្វើទារុណកម្ម ដែលមានចែងតាមលំដាប់លំដោយ នៅក្នុងមាត្រា៥០១ និង៥០៦ និងមាត្រា៥០០ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និង នៅក្នុងវិធាន៣ (ថ្មី) ២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ស្តីអំពីការបង្កើត អវតក [8]។

១៣. កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩ មេធាវីការពារក្តីបានលើកឡើងនៅក្នុងសារណាជាលាយលក្ខណ៍អក្សររបស់ខ្លួន ស្តីពីអញ្ញត្រកម្មបឋមទាក់ទងនឹងការរលត់ផុតទៅនៃបណ្តឹងអាជ្ញា ចំពោះរាល់បទឧក្រិដ្ឋតាមច្បាប់ជាតិដែលអនុវត្តតាម វិធាន៨៩ (១) (ខ) នៃវិធានផ្ទៃក្នុង [9]។

១៤. ក្រុមមេធាវីការពារក្តីបានគូសបញ្ជាក់រួចមកហើយនៅក្នុងសារណារបស់ខ្លួនថា ផ្អែកលើមាត្រាទី១០៩ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦[10] អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាចំពោះបទឧក្រិដ្ឋកម្រិតជាតិទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ បានផុតរលត់រួចទៅហើយ បើគិតមកដល់ថ្ងៃប្រកាសឲ្យប្រើ[11] មាត្រា៣ និង មាត្រា៣ (ថ្មី) (ទាំងពីរច្បាប់) នៃច្បាប់ស្តីពីការបង្កើត អវតក ដែលមាត្រាទាំងពីរនេះ បានពន្យារអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ។

---

[8] ឯកសារ D99/3/42, ERN 00270362-00270417។

[9] អញ្ញត្រកម្មបឋមស្តីអំពីការរលត់ផុតទៅនៃបណ្តឹងអាជ្ញាចំពោះបទឧក្រិដ្ឋស្របតាមច្បាប់ជាតិ ចុះថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០០៩ ឯកសារ E9/1, ERN 00276508-00276516 (« ឯកសារ E9/1 »).

[10] មាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ចែងថា ៖ "លើសពីដប់ឆ្នាំឡើងទៅក្រោយការប្រព្រឹត្តឧក្រិដ្ឋកម្ម ជនដែលពុំមានការផ្តន្ទាទោសទៀតឡើយ(...)"។

[11] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិសោធនកម្ម ថ្ងៃទី១០ សីហា ២០០១ និង ២៧ តុលា ២០០៤

១៥. អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្តីបានយល់ឃើញថា ជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** មិនអាចត្រូវបានជំនុំជម្រះដោយអង្គជំនុំជម្រះសាលាដំបូង ចំពោះឧក្រិដ្ឋកម្មមនុស្សឃាត និងបទល្មើសនៃការធ្វើទារុណកម្ម ដូចដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានទេ ពីព្រោះវាអាចប្រឈមមុខទៅនឹងការរំលោភលើវិធានអាជ្ញាបញ្ញា ក៏ដូចជារំលោភលើគោលការណ៍ជាសារវ័ន្តស្តីពីអនុភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌផងដែរ ។

១៦. កាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ក្រុមមេធាវីការពារក្តីបានដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបន្ថែម[12] ដើម្បីឆ្លើយតបទៅនឹងសំណួរពិសេសចំនួនប្រាំរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងអញ្ញត្រកម្មបឋម[13] ។

១៧. ផ្អែកលើគោលការណ៍ចម្បងទាំងនេះ ក្រុមមេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង មេត្តាយោងទៅលើសារណាស្តីអំពីអញ្ញត្រកម្មបឋម[14] ទាំងពីររបស់ក្រុមការពារក្តី និងទទួលយកសំណើនេះព្រមទាំងប្រកាសថា អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាចំពោះបទល្មើសមនុស្សឃាត និងបទល្មើសនៃការធ្វើទារុណកម្ម ដូចដែលមានចែងនៅក្នុងមាត្រា៥០០ មាត្រា៥០១ និងមាត្រា៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវបានផុតរលត់ហើយ ។

### *ខ. ជាលក្ខណៈបន្ថែម*

១៨. ក្នុងករណីវិសាមញ្ញ បើសិនអង្គជំនុំជម្រះសាលាដំបូងសម្រេចមិនទទួលយកអញ្ញត្រកម្មបឋមខាងលើនេះវិញ មេធាវីការពារក្តីសូមលើកឡើងពីមូលហេតុនៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះថ្ងៃទី៥ ខែ

---

[12] សារណាជាលាយលក្ខណ៍ស្តីពីអញ្ញត្រកម្មបឋម ដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី១៨ ឧសភា ២០០៩, E9/9, ERN 00332822-00332829 (« ឯកសារ E9/9 »).

[13] សេចក្តីណែនាំស្នើសុំឱ្យដាក់សារណាជាលាយលក្ខណ៍អក្សរស្តីអំពីអញ្ញត្រកម្មបឋម ស្នើឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី២០ មេសា ២០០៩, E9/4, ERN 00317962-00317964.

[14] សូមអានឯកសារ E9/1 et E9/9 ដែលរៀបរាប់ខាងលើ

ធ្នូ ឆ្នាំ២០០៨ ថា ៖ “ **ឌុច** មិនបានប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈការធ្វើទារុណកម្ម ដូចដែលមានចែងនៅក្នុងច្បាប់កម្ពុជា ដោយឈរលើមូលដ្ឋាននៃទម្រង់នៃការចូលរួម “ប្រព្រឹត្ត” ឡើយ[15]។

១៩. អង្គបុរេជំនុំជម្រះបានយល់ឃើញថា៖

*“កថាខណ្ឌចាប់ពី៩០ដល់៩៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះបានលើកឡើងពីធាតុផ្សំនៃភស្តុតាងនានា សំដៅបង្ហាញឱ្យឃើញថាឌុចបានប្រព្រឹត្តិទារុណកម្មដោយផ្ទាល់ដៃ ដែលជាទម្រង់នៃការប្រព្រឹត្តមួយដែលសហចៅក្រមស៊ើបអង្កេតបានកំណត់យក នៅក្នុងផ្នែកទាក់ទងនឹងបទចោទចំពោះអង្គហេតុ នៅកថាខណ្ឌទី ១៥៣។ តែទោះជាយ៉ាងណាក៏ដោយ ក៏អង្គបុរេជំនុំជម្រះមិនបានរកឃើញនៅក្នុងកថាខណ្ឌទាំងនេះ នូវអង្គហេតុជាក់លាក់ឱ្យបានគ្រប់គ្រាន់ល្មម ដើម្បីអនុញ្ញាតឱ្យខ្លួនអាចធ្វើការចោទប្រកាន់ជនត្រូវចោទ នៅចំពោះមុខតុលាការវិនិច្ឆ័យ ដោយឈរលើមូលដ្ឋាននៃទម្រង់នៃការចូលរួមប្រព្រឹត្ត[16] នោះឡើយ”។*

២០. ដូចគ្នានេះដែរ អង្គបុរេជំនុំជម្រះយល់ឃើញថា “អង្គហេតុដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនគ្រប់គ្រាន់ល្មមដើម្បីបង្ហាញឱ្យឃើញថា អំពើទារុណកម្មដែលបានចោទប្រកាន់នៅក្នុងដីកានេះ ត្រូវបានប្រព្រឹត្តឡើងយ៉ាងសាហាវព្រៃផ្សៃនោះទេ”[17]។

២១. អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្ដីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង មេត្តាប្រកាស និងវិនិច្ឆ័យថា អង្គជំនុំជម្រះសាលាដំបូងមិនលើកយកមកពិចារណា នូវបទឧក្រិដ្ឋកម្មតាមរយៈការប្រព្រឹត្តទារុណកម្មក្រោមទម្រង់នៃការចូលរួម “ប្រព្រឹត្ត” រួមទាំងអំពើទារុណកម្មដែលប្រព្រឹត្តឡើងដោយព្រៃផ្សៃនោះទេ។

## ខ. បទឧក្រិដ្ឋអន្តរជាតិ

---

[15] ឯកសារ D99/3/42, ERN 00270416.

[16] ឯកសារ D99/3/42, ERN 00270395, កថាខ័ណ្ឌ 100

[17] ឯកសារ D99/3/42, ERN 00270395, កថាខ័ណ្ឌ 101

២២. **ឌុច**ត្រូវបានសហចៅក្រមស៊ើបអង្កេតបញ្ជូនខ្លួនទៅជំនុំជម្រះក្តីនៅអង្គជំនុំជម្រះសាលាដំបូង ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ[18]។

### ក. *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ*

២៣. **ឌុច**បានទទួលស្គាល់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា លោកទទួលស្គាល់ថាមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅ ស-២១ ក្រោមការគ្រប់គ្រងរបស់គាត់[19] មែន។

២៤. អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្តីសូមពឹងផ្អែកលើគតិបណ្ឌិតរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីធានាឲ្យបានថា ធាតុផ្សំនៃបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដែលជាកម្មវត្ថុនៃការចោទប្រកាន់លើ**ឌុច** នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ ពិតជាមានលក្ខណៈគ្រប់គ្រាន់ជាក់ស្តែងមែន មុននឹងកំណត់ពីទំនួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មទាំងនេះ។

### ខ. ឧក្រិដ្ឋកម្មសង្គ្រាម

២៥. ក្រុមមេធាវីការពារក្តីសូមរំលឹកថា **ឌុច**មិនបានបដិសេធទាំងអត្ថិភាពនៃជម្លោះប្រដាប់អាវុធ រវាងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាម ទាំងទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់ចំពោះឧក្រិដ្ឋកម្មសង្គ្រាមដែលបង្កឡើងដោយជម្លោះនេះឡើយ ។

២៦. ទាក់ទងនឹងកាលបរិច្ឆេទពិតប្រាកដនៃថ្ងៃចាប់ផ្តើមជម្លោះប្រដាប់អាវុធអន្តរជាតិ រវាងកម្ពុជា និងវៀតណាម មេធាវីការពារក្តីពឹងផ្អែកទាំងស្រុងទៅលើគតិបណ្ឌិតរបស់អង្គជំនុំជម្រះសាលាដំបូង។ ក៏ប៉ុន្តែ

---

[18] ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៨ សីហា ២០០៨, D99, ERN 00210906.

[19] សូមអានប្រតិចារិកនៃសវនាការនាថ្ងៃទី៩ មិថុនា ២០០៩ , E1/29.1 (FR), ERN 00339476, បន្ទាត់ ទី៨ ដល់ ទី១៨

ក្រុមមេធាវីការពារក្ដីសូមបញ្ជាក់ថា មានភាពស្រពិចស្រពិលពាក់ព័ន្ធនឹងអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ មុនចុងឆ្នាំ១៩៧៧ ។

២៧. ពាក់ព័ន្ធនឹងប្រធានបទដដែលនេះ ក្រុមការពារក្ដីសូមបញ្ជាក់ថា អ្នកជំនាញលោក Nayan Chanda ដោយផ្អែកលើបទសម្ភាសន៍នានារបស់គាត់ជាមួយមេដឹកនាំវៀតណាម បានគូសបញ្ជាក់នៅអំឡុងពេលផ្ដល់សក្ខីកម្មរបស់គាត់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា នៅឆ្នាំ១៩៧៧ "អាជ្ញាធរក្រុងហាណូយមិនមានបំណងធ្វើសង្គ្រាមពិតប្រាកដណាមួយទេ"។ ក្រុងហាណូយគ្រាន់តែចង់ផ្ដល់សញ្ញាមួយចំនួនដល់ខ្មែរក្រហមតែប៉ុណ្ណោះ[20] ពោលគឺទើបតែនៅចុងឆ្នាំ ១៩៧៧ ទេ ដែល "វៀតណាមបានធ្វើការសន្និដ្ឋានថា វាមិនមែនជាបញ្ហាភ័ន្តច្រឡំរវាងគ្នា ឬបញ្ហាដំណោះស្រាយលើភាពមិនចុះសម្រុងមួយចំនួនពាក់ព័ន្ធនឹងព្រំដែននោះទេ[21]"។ ឆ្លើយតបទៅនឹងសំនួររបស់លោកស្រីចៅក្រម Cartwright លោក Nayan Chanda ក៏បានធ្វើការអះអាងផងដែរថា ការទម្លាក់គ្រាប់បែក និងការវាយលុកលុយទ្រង់ទ្រាយធំរបស់កម្លាំងវៀតណាម ទើបតែកើតមានឡើងនៅអំឡុងខែមិថុនា ឬកក្កដា ឆ្នាំ១៩៧៨ ប៉ុណ្ណោះ ពោលគឺនៅក្រោយការប្រកាសផ្ដាច់ទំនាក់ទំនងការទូត នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ [22]។

២៨. ដូច្នេះ ទោះជាយ៉ាងណាក្ដី មេធាវីការពារក្ដីយល់ឃើញថា ជនជាប់ចោទទើបតែបានទទួលដំណឹងថាមានជម្លោះប្រដាប់អាវុធអន្តរជាតិ រវាងរបបកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម ចាប់ពីថ្ងៃប្រកាសផ្ដាច់ទំនាក់ទំនងការទូត នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ប៉ុណ្ណោះ។ មេធាវីការពារក្ដីសូមគូសបញ្ជាក់ថា នៅក្នុងច្បាប់អន្តរជាតិ ការស្គាល់ព្រឹត្តការណ៍នៃអង្គហេតុដែលបង្ហាញពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធ គឺជាការចាំបាច់ក្នុងការរកឲ្យឃើញទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌពីបទឧក្រិដ្ឋកម្មសង្គ្រាម[23]។

---

[20] សូមអានប្រតិចារិកនៃសវនាការនាថ្ងៃទី២៥ ឧសភា ២០០៩, E1/24.1 (FR), ERN 00334219, បន្ទាត់ ទី១១ ដល់ ទី១៣

[21] សូមអានប្រតិចារិកនៃសវនាការនាថ្ងៃទី២៦ ឧសភា ២០០៩ , E1/25.1 (FR), ERN 00334795, បន្ទាត់ ទី៧ ដល់ ទី៩

[22]សូមអានប្រតិចារិកនៃសវនាការនាថ្ងៃទី២៥ ឧសភា ២០០៩ , E1/24.1 (FR), ERN 00334227, បន្ទាត់ ទី១៧ ដល់ ទី២៥

[23]ដើម្បីអាចចោទប្រកាន់លើទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទម្នាក់ពីបទឧក្រិដ្ឋកម្មសង្គ្រាមបាន លុះត្រាណាតែមានធាតុផ្សំទាំងនេះ ៖ អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ទំនាក់ទំនងរវាងបទឧក្រិដ្ឋដែលចោទប្រកាន់ និងជម្លោះប្រដាប់អាវុធ និងទាល់តែជនរងគ្រោះនៃជម្លោះនេះជាមនុស្សទទួលបានការពារដូចខ្លឹមសារដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ។ សូមអាន

២៩. ក្រុមមេធាវីការពារក្តីសូមបញ្ជាក់ថា ក្នុងសេចក្តីថ្លែងរបស់គាត់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត[24] និងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[25] ឌុចបានប្រាប់ថា គាត់មិនដែលបានដឹងអំពីទំនាស់ព្រំប្រទល់រវាង កម្ពុជា និងវៀតណាម មុនថ្ងៃ៣១ ខែធ្នូ ឆ្នាំ១៩៧៧ នោះទេ។

៣០. អត្ថិភាពនៃជម្លោះបែបនេះនៅក្នុងខេត្តមណ្ឌលគីរី ទាក់ទិននឹងបញ្ហាបន្ទាត់ Brevié ត្រូវបានអ្នកជំនាញ Nayan Chanda[26] បញ្ជាក់ថាពិតជាកើតមានប្រាកដមែន។ លោកបានលើកឡើងផងដែរថា ទំនាស់ទាំងនេះគ្រាន់តែជា "ការលបវាយឆ្មក់គ្នាតាមបែបធម្មតា[27]" រវាងប្រទេសទាំងពីរតែប៉ុណ្ណោះ តែមិនមែនជាជម្លោះប្រដាប់អាវុធអន្តរជាតិ ក្នុងន័យដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩[28] នោះឡើយ ។

៣១. ម្យ៉ាងវិញទៀត មេធាវីការពារក្តីយល់ឃើញថា ពាក្យសម្តីរបស់ឌុចគួរឲ្យជឿជាងគេ បើគិតពីការអនុវត្តដ៏ម៉ត់ចត់នូវគោលនយោបាយសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ ហើយក៏គួរឲ្យជឿថែមទៀត បើនិយាយពីបញ្ហាទំនាក់ទំនងរវាងកម្ពុជា និងវៀតណាម [29]។

---

រឿងក្តី *Le Procureur c./ Brdjanin* TPIY, សាលាដំបូង ថ្ងៃទី១ កញ្ញា ២០០៤ កថាខណ្ឌ ១២១។ លើសពីនេះទៅទៀត ត្រូវបង្ហាញឲ្យឃើញថា ជនជាប់ចោទបានដឹងអំពីព្រឹត្តិការណ៍នៃអង្គហេតុ "គឺបានន័យថា គាត់បានដឹងថារដ្ឋបរទេសជាភាគីមួយនៃជម្លោះប្រដាប់អាវុធនេះ"។ ទាក់ទងនឹងលក្ខណ:វិនិច្ឆ័យនេះ សូមអានរឿងក្តី *le Procureur c./ Kordic et Cerkez*, TPIY សាលាឧទ្ធរណ៍ ចុះថ្ងៃទី១៧ ធ្នូ ២០០៤ កថាខណ្ឌ ៣១១ និង សូមអានសេចក្តីអធិប្បាយលើមាត្រាទី៨ របស់លក្ខន្តិក:ទីក្រុងរ៉ូម នៅក្នុងធាតុផ្សំនៃបទឧក្រិដ្ឋនៃលក្ខន្តិក:ទីក្រុងរ៉ូម។

[24] *កំណត់ហេតុស្តួរចម្លើយ* ថ្ងៃទី៥ ឧសភា ២០០៨ ឯកសារ D72 (FR), ERN 00186170-00186171; *កំណត់ហេតុស្តួរចម្លើយ*, ៦ ឧសភា ២០០៨, D73 (FR), ERN 00186217 ;

[25] ប្រតិចារិកនៃសវនាការនាថ្ងៃទី២៥ ឧសភា ២០០៩, , E1/24.1(FR), ERN 00334263, បន្ទាត់ ១១ ដល់ ១៥.

[26] ប្រតិចារិកនៃសវនាការនាថ្ងៃទី២៥ ឧសភា ២០០៩, E1/24.1 (FR), ERN 00334232 បន្ទាត់ ១ ដល់ ១២.

[27] ប្រតិចារិកនៃសវនាការនាថ្ងៃទី២៥ ឧសភា ២០០៩, , E1/24.1(FR), ERN 00334227, បន្ទាត់ ៧ ដល់ ៨

[28] អនុសញ្ញាក្រុងហ្សឺណែវស្តីពីការប្រព្រឹត្តទៅលើឈ្លើយសឹក ចុះថ្ងៃទី១២ សីហា ១៩៤៩។

[29] សូមអានសក្ខីកម្មរបស់លោក Nayan Chanda ស្តីអំពីចំនុចនេះ : ប្រតិចារិកនៃសវនាការនាថ្ងៃទី២៥ ឧសភា ២០០៩ E1/24.1 (FR), ERN 00334227, បន្ទាត់ ៧ ដល់ ១៦ ; ប្រតិចារិកនៃសវនាការនាថ្ងៃទី២៥ ឧសភា ២០០៩ E1/24.1 (FR), ERN 00334275,

៣២. លើសពីនេះទៅទៀត ពាក្យសម្តីរបស់**ឌុច**ស្របគ្នានឹងពាក្យសម្តីរបស់សាក្សីឈ្មោះ **សួស ធី** ដែលសម័យនោះ លោកមានតួនាទីជាអ្នកចុះបញ្ជីឈ្មោះអ្នកទោសចូលនៅ ស-២១។ **សួស ធី** បានអះអាងថា *"ក្នុងឆ្នាំ១៩៧៦ ឬ ១៩៧៧ ពុំមានឈ្លើយសឹកជនជាតិវៀតណាមទេ។ គឺដល់ពេលជម្លោះប្រដាប់អាវុធផ្ទុះហើយទេ ទើបមានឈ្លើយសឹកវៀតណាមមកដល់។"*[30]

៣៣. លើសពីនេះទៅទៀត សេចក្តីថ្លែងទាំងនេះមានខ្លឹមសារសមស្របនឹង "បញ្ជីអ្នកទោសនៅ ស-២១ ដែលគេពិពណ៌នាថាជាទាហានវៀតណាម" នៅមន្ទីរ ស-២១ ។ បញ្ជីនេះត្រូវបានបញ្ចូលទៅក្នុងសំណុំរឿងដោយសហព្រះរាជអាជ្ញានៅក្រោមលេខកូដ E៦៨ (ឧបសម្ព័ន្ធ ២៨)[31]។ នៅក្នុងបញ្ជីនេះ យើងគួរកត់សំគាល់ថា ទំនងជាមានទាហានវៀតណាមតែពីរនាក់ប៉ុណ្ណោះដែលត្រូវបានចាប់ខ្លួន ហើយឃុំឃាំងនៅ ស-២១ មុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧។

៣៤. អាស្រ័យហេតុនេះ ដោយសារគោលនយោបាយសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជា និងដោយសារភាពស្ងាត់ស្ងៀមរបស់ប្រទេសកម្ពុជានិងវៀតណាមជុំវិញបញ្ហាអត្ថិភាព និងចរិតលក្ខណៈពិតនៃភាពតានតឹងរវាងប្រទេសទាំងពីរ ក៏ដូចជាភាពអវត្តមានរបស់ទាហានវៀតណាមនៅ ស-២១ មុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ នោះ មេធាវីការពារក្តីយល់ឃើញថា សហព្រះរាជអាជ្ញាមិនបានបង្ហាញអ្វីឲ្យបានលើសពីវិមតិសង្ស័យដែលថា **ឌុច**បានដឹងពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិរវាងប្រទេសទាំងពីរ មុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ នោះទេ។

## ខ. ឧក្រិដ្ឋនៃទំនួលខុសត្រូវ

---

បន្ទាត់ ១០ ដល់ ១២ ; ប្រតិចារិកនៃសវនាការនាថ្ងៃទី ២៥ ឧសភា ២០០៩ E1/24.1 (FR), ERN 00334217, បន្ទាត់ ៤ ដល់ ១៦ ; ប្រតិចារិកនៃសវនាការនាថ្ងៃទី២៥ ឧសភា ២០០៩ E1/24.1 (FR), ERN 00334236 បន្ទាត់ ៦ ERN 00334237 បន្ទាត់ ៨។ ចូរមើលផងដែរនូវសក្ខីកម្មរបស់លោក David Chandler ប្រតិចរិកនៃសវនាការនាថ្ងៃទី០៦ ខែ សីហា ឆ្នាំ ២០០៩ ឯកសារ E1/59.1 (FR), ERN 00361691, បន្ទាត់ ៣ ដល់ ១១។

[30] ប្រតិចារិកនៃសវនាការនាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០០៩ ឯកសារ E1/55.1 (FR), ERN 00357810, បន្ទាត់ ១៨ ដល់ ២០។

[31] ឯកសារ E68.28 (ឧបសម្ព័ន្ធ ២៨) ERN 00333629-00333635 (EN-KH)

### ១. ទំរង់នៃទំនួលខុសត្រូវដែល ឌុច មិនបដិសេធ

៣៥. វិធាន២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អវតក បានកំណត់ទម្រង់នៃទំនួលខុសត្រូវដូចជា ៖ ការប្រព្រឹត្ត ការបញ្ជា ការរៀបចំផែនការ ការញុះញង់ ការចូលរួមផ្សំគំនិត និង ទំនួលខុសត្រូវក្នុងឋានៈជាមេ។

៣៦. ដូចបានលើកឡើងនៅក្នុងកថាខ័ណ្ឌ១០រួចមកហើយ មេធាវីការពារក្តីសុំស្នើដល់អង្គជំនុំជម្រះសាលាដំបូងមេត្តាលើកលែង **ឌុច** ឱ្យរួចពីការចោទប្រកាន់ពីបទការប្រព្រឹត្ត ការរៀបចំផែនការ ការញុះញង់ និងការផ្សំគំនិត ព្រមទាំងធានាឱ្យបានថា ធាតុផ្សំផ្សេងៗដែលកំណត់ដោយច្បាប់ដើម្បីអនុវត្តលើទម្រង់ទំនួលខុសត្រូវ ដែលមានចែងនៅក្នុងវិធាន២៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អវតក ពិតជាមានគ្រប់លក្ខណៈ ដោយផ្អែកលើអង្គហេតុជាក់ស្តែង មុននឹងកំណត់ទំនួលខុសត្រូវព្រហ្មទណ្ឌរបស់ **ឌុច** ដោយឈរលើធាតុផ្សំទាំងនេះ។

៣៧. ទាក់ទងនឹងទំនួលខុសត្រូវក្រោមទម្រង់នៃ"**ការប្រព្រឹត្ត**"ចំពោះឧក្រិដ្ឋកម្មតាមរយៈការប្រព្រឹត្តទារុណកម្ម សូមមើលកថាខ័ណ្ឌទី១១ និង២១ ។

### ២. សហកម្មឧក្រិដ្ឋកម្មរួម

៣៨. យោងទៅតាមសេចក្តីសម្រេចចេញដោយអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២00៨ [32] និងសារណាដែលក្រុមការពារក្តីដាក់ទៅកាន់អង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២00៩ ដើម្បីឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលមានបំណងចង់ឱ្យអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម[33] ក្រុមមេធាវីការពារក្តីស្នើសុំឱ្យទាត់ចោលនូវការអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមជាទម្រង់នៃការចូលរួម ដែលសហព្រះរាជអាជ្ញាចង់អនុវត្តលើ **ឌុច**។

## IV. **ទំងន់ទោស**

---

[32] ឯកសារ D99/3/42

[33] ចម្លើយរបស់មេធាវីការពារក្តីតបទៅនឹងសំណូមពររបស់សហព្រះរាជអាជ្ញាដែលមានបំណងចង់ឱ្យអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២00៩, E73/2, ERN 00375013-00375025

**ក. អំពីស្ថានសម្រាលទោស**

៣៩. ក្រុមមេធាវីការពារក្តីស្នើសុំឱ្យផ្តល់ស្ថានសម្រាលទោសមួយចំនួនដល់ជនជាប់ចោទ។ មេធាវីការពារក្តីនឹងបរិយាយឱ្យពិស្តារអំពីស្ថានសម្រាលទោសទាំងនេះ នៅពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលដោយផ្ទាល់មាត់ ។

៤០. មេធាវីការពារក្តីសូមបញ្ជាក់ថា ទោះបីជាច្បាប់កម្ពុជាបានចែងជាទូទៅថា ស្ថានសម្រាលនឹងត្រូវបានចៅក្រមយកមកពិចារណា ក្នុងពេលកំណត់ទោស[34]ក៏ដោយ តែកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ និងច្បាប់ស្តីអំពីការបង្កើត អវតក ក៏ដូចជាវិធានផ្ទៃក្នុងរបស់ អវតក ពុំមានកំណត់បទបញ្ញត្តិណាមួយលើកឡើងពីស្ថានសម្រាលនេះទេ។

៤១. មេធាវីការពារក្តីបញ្ជាក់ថា អត្ថបទច្បាប់ស្តីអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិទាំងអស់សុទ្ធតែទទួលស្គាល់សិទ្ធិរបស់ជនជាប់ចោទក្នុងការស្នើសុំស្ថានសម្រាល ក្នុងករណីផ្តន្ទាទោស[35]។ ជាឧទាហរណ៍ តុលាព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ូវ៉ាន់ដា និង សម្រាប់ប្រទេសអតីតយូហ្គោស្លាវី បានចងក្រងយុត្តិសាស្ត្រដ៏គ្រប់ជ្រុងជ្រោយមួយ ស្តីពីអំពីស្ថានសម្រាលទោសនេះ ព្រមទាំងលើកឡើងពីប្រភេទនានានៃស្ថានសម្រាលទោស ដែលគេអាចជ្រើសរើសយកបានក្នុងពេលកំណត់ទោស ។

៤២. ដោយហេតុថាច្បាប់ព្រហ្មទណ្ឌកម្ពុជាពុំបានកំណត់អំពីស្ថានសម្រាលទោស សម្រាប់យកមកអនុវត្តចំពោះសំណុំរឿងនានាដែលក្នុងសំណុំរឿងនោះ ជនជាប់ចោទត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសពីបទ

---

[34] សូមអានមាត្រា១១៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលចែងថាទំងន់ទោសអាចសម្រាលបាន "បើសិនគេទទួលស្គាល់ថាមានស្ថានសម្រាលទោសនៅក្នុងបុព្វហេតុ" និងមាត្រា១២៧ នៃក្រមដដែលនេះ។ សូមអានផងដែរនូវមាត្រា៦៨ នៃច្បាប់អ៊ុនតាក់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ដែលចែងថា "ចៅក្រមត្រូវគិតអំពីស្ថានសម្រាល ដើម្បីកាត់បន្ថយទោសរហូតដល់ក្រោមកម្រិតទាបបំផុតនៃទោសដែលត្រូវអនុវត្ត (...)"

[35] សូមអាន វិធាន ១០១ (ខ) (ii) នៃវិធានស្តីពីភស្តុតាង និងនីតិវិធី របស់ TPIY, TPIR និង TSSL; មាត្រា ៧ (៤) នៃលក្ខន្តិកៈ របស់ TPIY និងមាត្រា ៦ (៤) នៃលក្ខន្តិកៈ របស់ TPIR និងវិធាន១៤៥ កថាខណ្ឌ១ (ខ) និង (គ) និង កថាខណ្ឌ ២ (ក) នៃបទវិធាននីតិវិធី និងភស្តុតាង របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋកម្មសង្គ្រាម ដូច្នេះ នៅពេលជជែកតវ៉ាចុងក្រោយដើម្បីសុំស្ថានសម្រាល មេធាវីការពារក្តីនឹងយោងទៅតាមយុត្តាធិការព្រហ្មទណ្ឌអន្តរជាតិដែលបានអនុវត្តក្នុងរឿងក្តីប្រហាក់ប្រហែលគ្នានឹងរឿងក្តីរបស់**ឌុច**នេះ ព្រមទាំងយោងផងដែរទៅនឹងវិធាន៣៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អវតក[36]។

## ខ. ការកាត់បន្ថយចំនួនឆ្នាំនៃការជាប់ពន្ធនាគារលើទំងន់ទោសដែលបានប្រកាស

៤៣. មេធាវីការពារក្តីសូមរលើកនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[37] ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ទាក់ទងនឹងសំណើសុំឲ្យដោះលែង**ឌុច**[38] របស់ក្រុមមេធាវីការពារក្តី។ នៅក្នុងសេចក្តីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងនៅក្នុងអំណះអំណាងសម្រេចរបស់ខ្លួនថា ៖ "ដោយផ្អែកលើច្បាប់អន្តរជាតិ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ជនជាប់ចោទមានសិទ្ធិទទួលបាននូវសំណងមួយសម្រាប់រយៈពេលដែលគាត់ត្រូវបានជាប់ឃុំឃាំងក្រោមអាជ្ញាធរនៃតុលាការយោធា និង ចំពោះការរំលោភសិទ្ធិរបស់គាត់។"[39]

៤៤. ក្នុងករណីដែលជនជាប់ចោទត្រូវបានកាត់ក្តីថាគ្មានពិរុទ្ធភាព អង្គជំនុំជម្រះសាលាដំបូងអាចចេញសេចក្តីសន្និដ្ឋានថា ជនជាប់ចោទអាចប្រើប្រាស់ផ្លូវច្បាប់ដែលសមស្របនឹងយុត្តាធិការកម្ពុជា ដើម្បីទទួលបាននូវសំណងសម្រាប់ព្យសនកម្មទាំងពីរខាងលើ ។

៤៥. ក្នុងករណីដែលជនជាប់ចោទត្រូវបានថ្កោលទោសនៅចំពោះមុខ អវតក និងដោយអនុវត្តមាត្រា៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា "ជនជាប់ចោទមានសិទ្ធិ

---

[36] ក្នុងករណីមានចន្លោះប្រហោង និងភាពមិនច្បាស់លាស់នៅក្នុងច្បាប់ជាធរមាន ឬក៏នៅក្នុងច្បាប់កម្ពុជា មាត្រា៣៣ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អវតក អាចឲ្យយោងទៅវិធាននីតិវិធីដែលទទួលស្គាល់ក្នុងកំរិតអន្តរជាតិ។

[37] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើសំណើសុំដោះលែង ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ E39/5, ERN 00338847-00338863 (« ឯកសារ E39/5)

[38] អំណះអំណាងបន្ថែមរបស់ក្រុមមេធាវីការពារក្តី ដើម្បីការពារសំណើរបស់ខ្លួនពាក់ព័ន្ធនឹងបញ្ហាទោស ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩ E39/3, ERN 00315426-00315429.

[39] ឯកសារ E39/5, ERN 00338862

ទទួលបាននូវការកាត់បន្ថយរយៈពេលដែលត្រូវជាប់ពន្ធនាគារ ដោយយករយៈពេលនេះដកនឹងរយៈពេលឃុំខ្លួនគាត់នៅក្រោមអាជ្ញាធរនៃអង្គជំនុំជម្រះវិសាមញ្ញ តាំងពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ មក"[40]។

៤៦. ក្រៅពីនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "ជាសំណង ជនជាប់ចោទមានសិទ្ធិទទួលបានផងដែរនូវការកាត់បន្ថយរយៈពេលដែលត្រូវជាប់ពន្ធនាគារ ដោយយករយៈពេលនេះដកនឹងរយៈពេលដែលគាត់ជាប់ឃុំឃាំងក្រោមអាជ្ញាធរនៃតុលាការយោធាតាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧" [41]។

៤៧. លើសពីនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់នៅកថាខណ្ឌចុងក្រោយនៃសេចក្តីសម្រេច[42] នេះថា នៅដំណាក់កាលកំណត់ទោស អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការសម្រេចជាស្ថាពរលើបែបផែន និងវិសាលភាពនៃសំណងបន្ថែមដែលអាចផ្តល់ជូនដល់ជនជាប់ចោទ ចំពោះការរំលោភសិទ្ធិរបស់គាត់ ។

៤៨. អាស្រ័យហេតុនេះ ក្រុមមេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តាប្រកាស និងវិនិច្ឆ័យថា ការរំលោភលើសិទ្ធិរបស់ឌុច ក្នុងការទទួលបាននូវការវិនិច្ឆ័យទោសក្នុងរយៈពេលកំណត់សមរម្យមួយ ឬសិទ្ធិក្នុងការទទួលបាននូវការដោះលែង ធ្វើឲ្យឌុចទទួលបានផងដែរនូវសិទ្ធិទទួលបាននូវសំណងមួយដែលសំណងនេះនឹងត្រូវទូទាត់ជាការកាត់បន្ថយចំនួនឆ្នាំដែលគាត់ត្រូវបានកាត់ក្តីឲ្យជាប់ពន្ធនាគារនោះ ហើយកិច្ចនេះក៏សមស្របនឹងការអនុវត្តគោលការណ៍ដែលដាក់នៅក្នុងរឿងក្តី *រដ្ឋអាជ្ញាប្រឆាំងនឹង Barayagwiza* នៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេស Rwanda (TPIR)[43] និង

---

[40] ឯកសារ E39/5, ERN 00338863 (មូលហេតុនៃសេចក្តីសម្រេច).

[41] ឯកសារ E39/5, ERN 00338863 (មូលហេតុនៃសេចក្តីសម្រេច).

[42] ឯកសារ E39/5, ERN 00338863 (មូលហេតុនៃសេចក្តីសម្រេច).

[43] សូមអានរឿងក្តីរវាង *រដ្ឋអាជ្ញា* និង លោក . *Barayagwiza*, នៅតុលាការ TPIR តុលាការកំពូល សាលដីកា (ទាក់ទងនឹងសំណើសុំធ្វើវិសោធនកម្ម ឬធ្វើការពិនិត្យឡើងវិញរបស់រដ្ឋអាជ្ញា) ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ២០០០ កថាខណ្ឌ ៧៤ និង៧៥ និងការ

ដែលត្រូវបានយកមកធ្វើជាមូលដ្ឋាននៅក្នុងការកាត់ក្តីក្រោយៗមកទៀត នៃតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗទៀតដែលសមស្រប[44]។

## V. ចម្លើយតបទៅនឹងសំណើសុំសំណងរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី

៤៩. ក្រុមមេធាវីការពារក្តីពុំជំទាស់នឹងសំណើសុំទាំងនេះទេ ។ ជាពិសេស មេធាវីការពារក្តីបានកត់ត្រានូវសំណើសុំសំណងរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្រោមទម្រង់ជា "ការចងក្រង និងការបោះពុម្ពពាក្យសំដីសុំទោសរបស់ឌុច ក្នុងអំឡុងពេលសវនាការ ដែលទទួលស្គាល់នូវការបង្កការឈឺចាប់ដល់ជនរងគ្រោះ"។

៥០. ម៉្យាងទៀត ក្រុមមេធាវីការពារក្តីចង់បញ្ជាក់ថា ឌុចត្រូវបានគេទទួលដឹងលឺថាជាអសាធនីយជន នៅពេលគេបញ្ជូនខ្លួនគាត់មកកាន់ អវតក។

---

ដាក់ឱ្យអនុវត្តសេចក្តីសម្រេចនេះរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសាលក្រមដែលប្រកាសនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៣ ("សាលក្រម និងការវិនិច្ឆ័យ") កថាខណ្ឌ១១០៦ និង១១០៧។ នៅក្នុងសាលក្រមនេះ បន្ទាប់ពីបានយល់ឃើញថាទោសសមស្របបំផុតសម្រាប់លោក *Barayagwiza* គឺទោសជាប់គុកមួយជីវិត អង្គជំនុំជម្រះសាលាដំបូងបានគិត ក្នុងដំណាក់កាលទីមួយ អំពីការរំលោភសិទ្ធិរបស់គាត់ ហើយបានបន្ថយទោសគាត់មកត្រឹមជាប់គុក៣៥ឆ្នាំវិញ។ បន្ទាប់មក ក្នុងដំណាក់កាលទីពីរ អង្គជំនុំជម្រះបានដកចំនួនឆ្នាំដែលគាត់ជាប់ឃុំឃាំងបណ្តោះអាសន្នចេញទៀត។ ដូច្នេះ នៅទីបញ្ចប់ លោក *Barayagwiza* ត្រូវបានប្រកាសឱ្យជាប់ទោសត្រឹមតែ ២៧ ឆ្នាំ ៣ ខែ និង២១ ថ្ងៃ។ ជាភាសាបារាំង សូមអាន (Voir *le Procureur c. Barayagwiza*, TPIR, Chambre d'Appel, Arrêt (relatif à la demande du Procureur en révision ou réexamen), 31 mars 2000, paragraphes 74 et 75, et la mise en application de cette décision par la Chambre de première instance, dans le Jugement du 3 décembre 2003 (« Jugement et sentence »), paragraphes 1106 et 1107, dans lequel la Chambre, après avoir considéré que la peine la plus appropriée à l'encontre de M. Barayagwiza était une condamnation à perpétuité, a dans un premier temps, pris en compte la violation de ses droits et a réduit cette peine à 35 ans d'emprisonnement, et, dans un second temps, a déduit le temps passé en détention provisoire. M. Barayagwiza fut donc finalement condamné à une peine d'emprisonnement de 27 ans, 3 mois et 21 jours.)

[44] សូមអានរឿងក្តី *Juvénal Kajelijeli* ទល់នឹងរដ្ឋអាជ្ញា តុលាការ TPIR អង្គជំនុំជម្រះសាលាកំពូល សាលដីកាចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០០៥ កថាខណ្ឌ ២៥៤ និង២៥៥ ព្រមទាំងកថាពី ៣២០ ដល់ ៣២៤។ ជាភាសាបារាំង (Voir, par exemple, l'affaire *Juvénal Kajelijeli c. le Procureur*, TPIR, Chambre d'appel, Arrêt d'appel du 23 mai 2005, paragraphes 254 et 255 ainsi que 320 à 324.)

## អាស្រ័យហេតុនេះ

៥១. ក្រុមមេធាវីការពារក្តីសូមស្នើអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **កត់ត្រានុកថា** ដោយពុំបានទទួលសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបញ្ចប់ការពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា និងរបស់ភាគីដទៃទៀតមុនថ្ងៃនេះ ក្រុមមេធាវីការពារក្តីសូមដាក់សារណានេះក្នុងទម្រង់បច្ចុប្បន្ននេះ និងសូមរក្សាសិទ្ធិដាក់ជូនអំណះអំណាងបន្ថែមទាំងអស់ដោយផ្ទាល់មាត់។

- **ប្រកាស និង សម្រេចថា** ការទទួលស្គាល់អង្គហេតុរបស់**ឌុច** គឺជាការសារភាពមួយ ហើយការសារភាពនេះ គឺជាភស្តុតាងមួយក្នុងចំណោមភស្តុតាងទាំងអស់ដែលទទួលស្គាល់ដោយវិធានផ្ទៃក្នុងរបស់ អវតក និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

- **ប្រកាស និង សម្រេចថា** អង្គហេតុដែលឌុចជំទាស់ មិនត្រូវបានបកស្រាយឲ្យបានច្បាស់លាស់ឲ្យលើសពីវិមតិសង្ស័យដែលមានស្រាប់តែប៉ុណ្ណោះនោះទេ ព្រមទាំង**ប្រកាស**លើកលែងការចោទប្រកាន់**ឌុច**លើអង្គហេតុទាំងនេះ រួមមានបទចោទប្រកាន់ដែលថា:
  - **ឌុច** ទំនងជាបានសម្លាប់អ្នកទោសនៅ ស-២១ ដោយផ្ទាល់ដៃ
  - **ឌុច** ទំនងជាបានធ្វើទារុណកម្មអ្នកទោសនៅ ស-២១ ដោយផ្ទាល់ដៃ
  - **ឌុច** ទំនងជាបានបញ្ជាឲ្យចាប់ខ្លួនមនុស្ស ដោយគ្មានការណែនាំពីថ្នាក់លើរបស់គាត់។

- **ទទួលយក**សារណារបស់មេធាវីការពារក្តីស្តីពីអញ្ញត្រកម្មបឋម និង **ប្រកាស**ពីការផុតរលត់នៃបណ្តឹងអាជ្ញាសម្រាប់អំពើឃាតកម្ម និងទារុណកម្ម ដូចមានចែងក្នុងមាត្រា៥០០ មាត្រា៥០១ និងមាត្រា៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។
- ដោយផ្អែកលើសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចេញថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ **ប្រកាស និង សម្រេចថា** អង្គបុរេជំនុំជម្រះមិនលើកយកមកពិចារណា នូវបទឧក្រិដ្ឋកម្មតាមរយៈការប្រព្រឹត្ត

ទារុណកម្ម ក្រោមទម្រង់នៃការចូលរួម"ប្រព្រឹត្ត" ព្រមទាំងអំពើទារុណកម្មដែលបានប្រព្រឹត្តយ៉ាងព្រៃផ្សៃនោះទេ។

- **កត់ត្រានូវថា** ការទទួលស្គាល់របស់ឌុច ពីទំនួលខុសត្រូវរបស់គាត់ ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តនៅ ស-២១ មានការពាក់ព័ន្ធនឹងទម្រង់នៃការចូលរួម "បញ្ជា" និង "ទំនួលខុសត្រូវក្នុងនាមជាមេ" ហើយគាត់បានសារភាពកំហុសទាក់ទងនឹងបទចោទប្រកាន់ទាំងនេះ។

- **ប្រកាស និង សម្រេចថា** សហព្រះរាជអាជ្ញាមិនបានបង្ហាញពីទម្រង់នៃការចូលរួមផ្សេងទៀត ក្រៅពីវិមតិសង្ស័យដែលមានតែប៉ុណ្ណោះ។

- **ប្រកាស** លើកលែងការចោទប្រកាន់ឌុច ពីទម្រង់នៃទំនួលខុសត្រូវលើបទប្រព្រឹត្ត ការរៀបចំផែនការ ការញុះញង់ និងការផ្សំគំនិត។

- **ទទួលយក** សារណារបស់ក្រុមមេធាវីការពារក្តី ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម **និង បដិសេធចោល** ការអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមនៅក្នុងរឿងក្តីនេះ។

- **ប្រកាស និង សម្រេចថា** ជនជាប់ចោទទទួលបាននូវស្ថានសម្រាលទោស ។

- **បន្ថយទោស**ជនជាប់ចោទ ដោយទូទាត់សងជាមួយរយៈពេលសរុបនៃការឃុំខ្លួនបណ្តោះអាសន្ន របស់ឌុច ចាប់តាំងពីថ្ងៃដែលគាត់ជាប់ឃុំនៅពន្ធនាគារយោធានៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃប្រកាសសាលក្រម ។

- **បន្ធូរទោស**ជនជាប់ចោទ ដែលបានប្រកាសថាត្រូវជាប់ឃុំអស់រយៈពេលប៉ុន្មានឆ្នាំបន្ថែមទៀតនោះ ដើម្បីទូទាត់សងនឹងការរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្នុងរយៈពេលមួយសមរម្យ ឬ ទទួលការដោះលែងដោយសារការឃុំខ្លួនលើសកាលកំណត់ ។

## សុំរក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

| | | | |
|---|---|---|---|
| 11-11-2009 | សហមេធាវីទាំងពីរ<br><br>មេធាវី **ការ សាវុត្ថ**<br><br>មេធាវី **François ROUX** | ភ្នំពេញ | [signature] |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |